# រឿង មហាចោរនៅទល់ដែន

**ភាគទី៦៣** (ក្បួនការពារឯករាជ្យ)

អឺ! បងសល់តែអនុស្សាវរីយ៍គាត់ទេ! ប្អូនដឹងទេ? គាត់ទៅណាហើយៗ ទៅនៅព្រៃ? ទេ! គាត់ទៅ...ទៅ...ឪទៅស្ថានដែលមនុស្សលែងវិលត្រឡប់មកវិញ...ទៅនៅស្ថានលើ! ស្ថានក្រោម! ស្ថានមរណៈ! ស្ថានខ្មោច! វាស្លាប់ហើយ!

នាងមាលាពាដៃ បើកភ្នែកក្រឡោត ដង្ហើមទាញឮដឹក

ស្លាប់...ស្លាប់ហើយ!

ព្រះនាងឆ្លើយតបមួយៗ៖

អឺ! វាស្លាប់ហើយ! ស្លាប់បួនថ្ងៃហើយ វាស្លាប់យ៉ាងអស្ចារ្យណាស់! ស្លាប់ក្នុងជុចដូចត្រី! ស្លាប់នឹងដៃខ្ញុំៗ ពីថ្ងៃនេះទៅ ខ្ញុំលែងបានឃើញមុខខ្មាំងដ៏ធំបំផុត ដែលខ្ញុំស្រលាញ់នេះហើយៗ ពីថ្ងៃនេះទៅ បងកាមារស់បានដោយស្រួលត្បិតគាត់លែងបានឮឈ្មោះសត្រូវរបស់គាត់នេះទៀតហើយៗ

ព្រះនាងបិទភ្នែកផ្តួលខ្លួនទៅលើពូកជាថ្មីម្តងទៀតៗ

នាងមាលាចង់សាកសួរព្រះនាងតទៅទៀតណាស់ អំពីដំណើរយ៉ាងណាក៏ចាប់មានទ្ធបានរួចតើស្លាប់ក្នុងជុចនោះ ស្លាប់បែបណា? តែព្រះនាងនៅស្ងៀម នាងក៏ហើបមាត់សួរពុំឆ្លើយៗ ស្រីទាសីសុខចិត្តខំអត់សង្កត់ចិត្តក្រែងលោព្រះនាងដឹងថាមកបម្រើនេះ គ្មានអ្វីក្រៅពីមកស៊ើបការណ៍ទេៗ

ព្រះនាងងើបអង្គុយឡើងជាថ្មី មានទឹកមុខមានទឹកមុខដ៏ក្រៀមក្រោះដែលដូចមុនហើយបន្តកិច្ចចរចាសម្ងាត់ដូចខាងក្រោមនេះ៖

ចាំះ! ប្អូនៗ! ខ្ញុំព្រួយមែន តើប្អូនដឹងការរាក់ជ្រៅក្នុងអាណាខេត្តយើងអស់ទេ?

នាងមាលាដាក់ភ្នែកចុះ ឆ្លើយដោយរាយមាយថា:

ទេ!

ចាំបងប្រាប់! អើបងប្រាប់អោយអស់ថ្ងៃនេះ ត្បិតពេលផ្តាច់ព្រ័ត្រមកដល់ហើយៗ

អត្ថបទដោយ៖ មាស សុភាព

*បងមានផែនការបីយ៉ាង: ផែនការទីមួយគឺសម្លាប់បងមានន្ទអោយបាន! ឥឡូវផែនការនេះស៊ឹងបានសម្រេចដូចបំណងបងស្រេចៗ បន្តិចទៀតក្នុងថ្ងៃស្អែក គឺកាលណាយើងទៅដល់ស្រុកមង្គលបុរីបងនឹងអនុវត្តផែនការណ៍ទីពីរៗ*

*គឺអ្វី?*

*គឺសម្លាប់ព្រះកម្ពុតជាមាបងចោល!*

*ហ៎ ម៉េចក៏ចុះ?*

*ហាស៎ៗ! អូននៅខ្ចីណាស់! អូនមិនយល់ទេ! ត្បិតព្រះកម្ពុតធ្វើការមិនរហ័សដូចចិត្តសោះៗ មនុស្សចាស់គិតយូរ ចាត់ការមិនល្អ! ដើរមិនទាន់សម័យ! ដំណើរយឺត! ចិត្តសាញ! ខ្លាច! រឿងនេះព្រះកម្ពុតជារនាំងស្ទះផ្លូវ មិនឲ្យការងារជាប្រយោជន៍សម្រេចបានៗ*

*ចុះរដ្ឋាភិបាលព្រះចៅសៀមថាយ៉ាងណាទៅបើដល់ព្រះកម្ពុតស្លាប់នោះ? ក្រែងអ្នកជំនួសក្រោយចិត្តមិនបានដូចព្រះកម្ពុតឬ?*

*ហ៊ឺ! ឆោតមែន! សព្វថ្ងៃបងកាមាបម្រុងនឹងកាន់កាប់ការជំនួសព្រះកម្ពុតទាំងអស់ៗ និលពេជ្រនឹងទៅជាមេទ័ពជំនួសបងកាមានេះឯងៗ និលឯកនឹងទៅជាមេទ័ពទៀតៗ យើងទាំងអស់គ្នាយល់ព្រមគ្នាជាស្រេចហ៎ាសៗ! ជាស្រេច! សម្លាប់ព្រះកម្ពុតហើយ រួចរាជការមុខជាចាត់បងកាមាដើម្បីបន្តការងារមិនខានៗ*

*ចុះបើគេមិនតាំង?*

*អើធ្លាតគ្រាន់បើ! តែដើម្បីដោះស្រាយចំណោទនេះ តោងដឹងផែនការទីបីរបស់យើងទៀតៗ បីថ្ងៃមកហើយ ពួកយើងបានលួចទ្រព្យសម្បត្តិរបស់ព្រះកម្ពុតអស់រលីងៗ លួចបាននោះទ្រព្យធំៗមានមាសប្រហែល៣ហាប ប្រាក់ប្រហែល៥ហាបៗ យើងអោយពួកយើងធ្វើចោរ "មានន្ទ" ដែលទៅប្លន់ប្រាសាទព្រះកម្ពុតៗ ឥឡូវមាសនោះនៅក្នុងកណ្តាប់ដៃយើងអស់ហើយៗ ឥឡូវប្រាសាទព្រះកម្ពុតទៅផេះអស់រលីងៗ ឥឡូវព្រះកម្ពុតជាអ្នកក្រ រួចនៅតែស្លាប់ខ្លួនទៀតតែប៉ុណ្ណោះៗ*

*អូ! ខ្ញុំឮគេខ្សឹបខ្សៀវគ្នាថា មានចោរប្លន់សិរីសោភ័ណនោះមែនឬទេ?*

*នុ៎ះឯង! កុំមាត់! នៅឲ្យស្ងៀម! កុំឲ្យឮច្រើនគ្នាៗ*

*អត្ថបទដោយ៖ មាស សុភាព*

អើបន្តិចទៀត! បងផុតទុក្ខហើយ! រួចបងទេជាអគ្គមហេសីស្តេចសឹកក្មេងមួយអង្គដែលអូនស្គាល់ស្រាប់ គឺបង កាមានេះឯង!

លោកកាមាសុខចិត្តសម្លាប់ឪពុកលោកដែរ?

ព្រះនាងញញឹមងក់ក្បាល:

ព្រះពុទ្ធលោកថា បុណ្យសក្តិ លោភោ ទោសោ មោហោ អំពើទាំងនេះ បិទភ្នែកមនុស្សឲ្យលែងឃើញវត្ថុត្រូវ។ អំពើទាំងនេះ បិទខួរក្បាលមនុស្សឲ្យគិតលែងត្រូវ! ទេ! ទេ! គ្មានព្រះគ្មានអាទិទេពឯណាទេ គឺមនុស្សៗធ្វើការមនុស្សឈ្នះ។ មនុស្សខ្លាំងពូកែត្រូវតែដឹកក្បាលមនុស្សខ្សោយរាប់លាន់នាក់បាន។

ថាហើយព្រះនាងផ្តួលខ្លួនទៅលើពូកជាលើកទីបី ក្នុងព្រះរាជរថយើងបរយឺតៗតាមផ្លូវមកស្រុកថ្មគោល។

នៅថ្មគោលយប់នោះឯទីផ្សារល្បែងផងទាំងពួងបន្ទីស្គរ និងសំរែកទ្រហឹងអឺងកងក្រោមពន្លឺចន្ទុះព្រោងព្រាត។ មនុស្សដើរខ្វែងខ្វាត់ចុះឡើងៗមីរដេរដាស។ អ្នកលក់ម្ហូបចំណីអង្គុយត្រៀបត្រាជាជួរ។

ព្រះនាងមណី កាមា ព្រះកម្ពុត នៅសម្រាកក្នុងគេហដ្ឋានមួយដ៏ស្តុកស្តមជាងគេជាធម្មតាហើយជាធម្មតាមានទាហានយាមឥតធ្វេសប្រហែសមួយនាទីឡើយ។

ក្នុងហ្វូងអ្នកស្រុកដែលកំពុងអ៊ូរអរ មានជនប្រាំនាក់ដើរបន្ទំជាមួយគេឯង តែភ្នែករវៀសប្រុងមើលឆ្វេងស្តាំជានិច្ច។ ជនចម្លែកទាំងប្រាំនាក់ គឺមហាកាល អារុណ វីរៈ នាយកត និងនាយឡំ។

**(សូមរង់ចាំតាមដានភាគទី៦៤ នៅសប្តាហ៍ក្រោយ)**

អត្ថបទដោយ៖ មាស សុភាព